# ជំពូកទី ១

Draft

# ជំពូកទី ១: សេចក្តីផ្តើម

## ១.១ ប្រវត្តិ

គំរោង **មរកត** ជាគំរោងវិនិយោគស្របច្បាប់មួយរបស់ក្រុមហ៊ុនឯកជន ឈ្មោះ **កោះពស់ (ខេមបូឌា) អ៊ិនវេសមេនគ្រុប អិលធីឌី** ដោយផ្អែកលើកិច្ចសន្យាដើមរវាងរាជរដ្ឋាភិបាលកម្ពុជា (RGC) និងក្រុមហ៊ុនកោះពស់ (ខេមបូឌា) អ៊ិនវេសមេនគ្រុប អិលធីឌី (KPIG) ស្តីពីការជួលកោះពស់ និងឆ្នេរហាវ៉ៃ រយៈពេល៩៩ឆ្នាំ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៦ (ឧបសម្ព័ន្ធ ២ក)។

ក្នុងផែនការមេនៃគំរោងអភិវឌ្ឍន៍នេះមានសមាសធាតុចំបងបីគឺ ការសាងសង់ស្ពានកោះពស់ ការអភិវឌ្ឍលើកោះពស់ និងការអភិវឌ្ឍលើឆ្នេរហាវ៉ៃ។ កោះពស់ និងឆ្នេរហាវ៉ៃខ័ណ្ឌចែកដោយឃ្លងធម្មជាតិ ដែលមានទទឹងប្រមាណជា ៧០០ម៉ែត្រ ហើយដែលប្រជាជនអាចទៅកោះពស់នេះបានតាមទូក ឬទូកម៉ាស៊ីន។ ប៉ុន្តែ តំបន់កោះពស់នេះមានសក្តានុពលយ៉ាងខ្លាំងចំពោះការអភិវឌ្ឍវិស័យទេសចរណ៍ ដោយសារភាពសំបូរបែបនៃធនធានធម្មជាតិ រាប់ទាំងឆ្នេរដ៏ធំទូលាយ ជាមួយនឹងខ្សាច់ពណ៌សល្អស្អាត ទឹកថ្លាស្អាត និងព្រៃឈើដ៏ត្រឈឹងត្រឈៃ។

ជាការចាប់ផ្តើមអភិវឌ្ឍន៍តំបន់កោះពស់នោះ ការសាងសង់ស្ពានកោះពស់ត្រូវបានផ្តើមធ្វើជាក់ស្តែងនៅឆ្នាំ ២០០៨ ហើយការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូងសំរាប់គំរោងត្រូវបានអនុវត្តតាមការទាមទារនៃច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា។ នៅចុងឆ្នាំ២០០៨ របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូងសំរាប់គំរោងត្រូវបានឯកភាពជាគោលការណ៍ ដោយក្រសួងបរិស្ថាននៃរាជរដ្ឋាភិបាលកម្ពុជា (មើលលិខិតលេខ ៥៨៨ សជណ បស្ថ. ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៨, ឧបសម្ព័ន្ធ ៤)។

## ១.២ គោលបំណងរបាយការណ៍

ផ្អែកតាមច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា (ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ១៩៩៦) និងអនុក្រឹត្យ ស្តីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន (ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ១៩៩៩) ហើយនឹងការផ្តល់អនុសាសន៍ពីក្រសួងបរិស្ថាន និងអន្តរក្រសួង ក្នុងការឯកភាពសំរេចលើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូងនៅចុងឆ្នាំ២០០៨ នោះ**គំរោងមរកត** ចាត់ជាប្រភេទគំរោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធធំៗ ដែលតំរូវឱ្យមានការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ (វ.ហ.ប)។

គោលបំណងនៃរបាយការណ៍នេះគឺ បង្ហាញពីលទ្ធផលសិក្សា វ.ហ.ប សំរាប់គមរោងអភិវឌ្ឍន៍ទាំងមូល ចំពោះហេតុប៉ះពាល់ដោយផ្ទាល់ និងដោយប្រយោល ទាំងផលវិជ្ជមាន និងអវិជ្ជមាន ទៅលើធនធានធម្មជាតិ និងធនធានសង្គមនៅក្នុងនិងនៅជុំវិញតំបន់គំរោង។

Draft

ការសិក្សានឹងពិនិត្យមើលពីសក្តានុពលនៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ហើយនិងរៀបចំនូវវិធានការកាត់បន្ថយសំរាប់ហេតុប៉ះពាល់អវិជ្ជមាននិមួយៗនៅពេល មុនសាងសង់ សាងសង់ និងដំណើរការគំរោង។ ការវាយតំលៃត្រូវបានធ្វើឡើងដោយអនុលោមទៅតាមច្បាប់នៃកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិរបស់ព្រះរាជាណាចក្រកម្ពុជា អនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងគោលការណ៍សំរាប់ការធ្វើ ហ.វ.ប ព្រមទាំងបទបញ្ញត្តិ និងច្បាប់ពាក់ព័ន្ធផ្សេងៗទៀត។

របាយការណ៍សិក្សា EIA ពេញលេញនឹងត្រូវដាក់រួមគ្នាជាមួយ និងរបាយការណ៍សិក្សាសមិទ្ធិលទ្ធភាពគំរោងជូនទៅក្រសួងបរិស្ថាន និងអន្តរក្រសួង ដើម្បីអនុម័តមុនពេលគំរោងចាប់ ផ្តើមសាងសង់ និងប្រតិបត្តិការ។ ទន្ទឹមនោះដែរ របាយការណ៍សិក្សាសមិទ្ធិលទ្ធភាពគំរោង និងប្លង់វិស្វកម្មលំអិតនឹងត្រូវដាក់ជូនទៅក្រសួងពាក់ព័ន្ធដូចជា ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ដែលជាក្រសួងជំនាញទទួលបន្ទុកពិនិត្យអនុម័តលើលក្ខណៈបច្ចេកទេស និងការងារវិស្វកម្មផ្សេងៗ។ ឯកសារអនុម័តទាំងពីរនឹងជាឯកសារសំខាន់ រួមជាមួយឯកសារវិនិយោគទុនផ្សេងៗទៀតដែលត្រូវដាក់ស្នើទៅរាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីផ្តល់សិទ្ធិអនុញ្ញាតឱ្យដល់ក្រុមហ៊ុនវិនិយោគ **កោះពស់ (ខេមបូឌា) អ៊ិនវេសមេនគ្រុប អិលធីឌី** ក្នុងការអនុវត្តន៍គំរោង។

## ១.៣ គោលបំណងសេដ្ឋកិច្ចសង្គមនិងបរិស្ថានរបស់គំរោង

គោលបំណងចំបងរបស់**គំរោងមរកត** គឺដើម្បីទាញយកផលប្រយោជន៍ពីធនធានធម្មជាតិក្នុងតំបន់កោះពស់ ដើម្បីរួមចំណែកកសាងសេដ្ឋកិច្ចជាតិនៃព្រះរាជាណាចក្រកម្ពុជា។ ការសាងសង់ស្ពានកោះពស់ នឹងជាមធ្យោបាយដ៏ប្រសើរមួយភ្ជាប់ដីគោកទៅកោះក្នុងក្រុងព្រះសីហនុ ដែលជាធនធានដ៏មានសក្តានុពលក្នុងការអភិវឌ្ឍវិស័យទេសចរណ៍។ ជាមួយហេដ្ឋារចនាសម្ព័ន្ធចំរុះ បណ្តាញផ្លូវថ្នល់ សំណង់សម័យទំនើប វាលវាយកូនគោល និងរមណីដ្ឋាននៅលើកោះពស់នឹងធ្វើឱ្យប្រសើរឡើងថែមទៀតនូវតំលៃធនធានបរិស្ថាន។ ជាមួយនឹងសំណង់សម័យទំនើបដូចជា សណ្ឋាគារលំដាប់ផ្កាយប្រាំ និងកន្លែងសំរាកវិស្សមកាល នឹងបង្កើនការទាក់ទាញដល់តំបន់ឆ្នេរសមុទ្រ។ សមាសធាតុទាំងឡាយនៃ**គំរោងមរកត** នឹងបន្ថែមនូវហេដ្ឋារចនាសម្ព័ន្ធសម័យទំនើបចំពោះទីក្រុងព្រះសីហនុ ដែលនឹងធ្វើឱ្យតំបន់កោះពស់ប្រសើរឡើង និងជាកន្លែងកាន់តែទាក់ទាញដល់ភ្ញៀវទេសចរណ៍។

គោលបំណងគំរោងលើផ្នែកសង្គមរួមមាន: (១) ចូលរួមចំណែកក្នុងផែនការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៃក្រុងព្រះសីហនុ ដូចជា ប្រព័ន្ធគមនាគមន៍ (ផ្លូវ ស្ពាន) អាគារសម័យទំនើប (សណ្ឋាគារ មជ្ឈមណ្ឌលពាណិជ្ជកម្ម សាលារៀន មន្ទីរពេទ្យ ប៉ូរីរដ្ឋបាល។ល។), (២) លើកកំពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ដោយបង្កើតការងារ និងប្រាក់ចំណូលប្រចាំថ្ងៃផ្ទាល់ ជាបុគ្គលិក/កម្មករគំរោង និងដោយប្រយោលពីសកម្មភាពទេសចរណ៍ក្នុងតំបន់ទាំងមូល។ គោលបំណងខាងលើនេះគឺ ស្របតាម "**យុទ្ធសាស្ត្រចតុកោណ**" **ដើម្បីកំណើន ការងារ សមធម៌ និង**



Draft

**ប្រសិទ្ធភាព នៅកម្ពុជា**-ដំណាក់កាលទី២ នៅលើជ្រុងទី២ " ***ការស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត*** " និងជ្រុងទី៣ " ***ការអភិវឌ្ឍវិស័យឯកជន និងការងារ*** " ។ សមិទ្ធិផលរបស់គមរោងនេះ នឹងផ្តល់ឱ្យនូវហេដ្ឋារចនាសម្ព័ន្ធទំនើប ងាយស្រួល វិសេសវិសាល និងសុវត្ថិភាពដល់ប្រជាពលរដ្ឋក្នុងក្រុងព្រះសីហនុ និងភ្ញៀវទេសចរណ៍ ហើយសំរួលផ្នែកពាណិជ្ជកម្ម និងលើកតំកើនផ្នែកទេសចរណ៍ក្នុងតំបន់ទាំងមូល ព្រមទាំងធ្វើឱ្យមានការរីកចំរើនផ្នែកសេដ្ឋកិច្ចជាតិទៀតផង ។

## ១.៤ ទំហំដែន និងមាតិកាសង្ខេបរបាយការណ៍

ទំហំដែននៃការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថានគ្របដណ្តប់ទាំងគុណប្រយោជន៏របស់បរិស្ថាន និងសង្គមលេចចេញពីគ្រប់ទិដ្ឋភាពទាំងអស់របស់គំរោងនៅក្នុងការកំណត់យ៉ាងទូលំទូលាយនៃចំណាត់ថ្នាក់ធនធានបរិស្ថាន និងគុណតំលៃរបស់វាក្នុងតំបន់គំរោងដូចជា:

- បរិស្ថានរូបសាស្ត្ររួមមាន ដី ទឹក និង បរិយាកាស ។
- បរិស្ថានជីវសាស្ត្ររួមមាន សត្វនិងរុក្ខជាតិដែលរស់នៅលើផែនដីនិងនៅក្នុងទឹក ព្រមទាំងជំរករបស់វា ។
- បរិស្ថានសង្គម ដែលរាប់បញ្ចូលនូវ ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត សេវាកម្ម និងមធ្យោបាយបំរើឱ្យសុខុមាលភាព ការងារ ការអប់រំ ការអភិវឌ្ឍសេដ្ឋកិច្ចទូទៅ ។
- តំបន់វប្បធម៌ វត្ថុបុរាណ និងគុណភាពតំលៃនៃការរស់នៅក្នុងតំបន់គំរោង ។

មាតិកាសង្ខេបនៃរបាយការណ៍នេះរួមមានប្រាំបួនជំពូក: ប្រវត្តិរបស់គំរោងមានរៀបរាប់នៅជំពូកទី១ ។ ស្ថាប័ន និងក្របខ័ណ្ឌច្បាប់ដែលទាក់ទងទៅនឹងប្រភេទនិងសកម្មភាពទាំងឡាយរបស់គំរោងមានបង្ហាញក្នុងជំពូកទី២ ។ ការពិណនាជាទូទៅពីទីតាំង សមាសធាតុ និងវិសាលភាពរបស់គំរោងមានរៀបរាប់នៅក្នុងជំពូកទី៣ ។ ស្ថានភាពដើមដែលទាក់ទងទៅនឹងធនធានបរិស្ថាន និងធនធានសង្គមដែលមានស្រាប់មានរៀបរាប់ក្នុងជំពូកទី៤ ។ ការជួបប្រជុំជាសាធារណៈ និងការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនឹងគំរោងនិងប្រជាជនដែលទទួលរងផលប៉ះពាល់ មានរៀបរាប់នៅក្នុងជំពូកទី៥ ។ នៅក្នុងជំពូកទី៦មានរៀបរាប់ពីការវាយតំលៃទៅលើហេតុប៉ះពាល់បរិស្ថាន និងវិធានការបន្ធូរបន្ថយ ។ ផែនការគ្រប់គ្រងបរិស្ថាន មានរៀបចំនៅក្នុងជំពូកទី៧ ហើយការវាយតំលៃពីសេដ្ឋកិច្ចសំរាប់គំរោងមានពណ៌នានៅក្នុងជំពូកទី៨ ។ នៅចុងបញ្ចប់គឺជំពូកទី៩ ដែលមានរៀបរាប់ពីសេចក្តីសន្និដ្ឋាន ទៅលើការសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថានទាំងមូល ។

## ១.៥ វិធីសាស្ត្រ

មាតិកានៃរបាយការណ៍ វ.ហ.ប គឺអនុលោមទៅតាមអនុក្រឹត្យ ស្តីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថានរបស់រាជរដ្ឋាភិបាលកម្ពុជា និងគោលការណ៍ណែនាំសំរាប់រៀបចំរបាយការណ៍ វ.ហ.ប របស់ក្រសួងបរិស្ថាន ខែកញ្ញា ឆ្នាំ២០០៩ ។

Draft

ការ វ.ហ.ប គឺគិតគូរទៅលើអន្តរអំពើរវាងសមាសធាតុគំរោង និងលក្ខណៈបរិស្ថាន។ អន្តរអំពើផ្តល់នូវការកើតឡើងទាំងហេតុប៉ះពាល់វិជ្ជមាន និងគុណប្រយោជន៍។ ផលប្រយោជន៍ផ្សេងៗត្រូវបានកត់សំគាល់ និងក្នុងករណីខ្លះមានដាក់ក្នុងការវិភាគសេដ្ឋកិច្ចបរិស្ថាន។ ហេតុប៉ះពាល់អវិជ្ជមាននឹងត្រូវកាត់បន្ថយតាមរយៈការរៀបចំប្លង់គំរោង និងតាមរយៈការអនុវត្តការងារជាក់ស្តែង។ វិធានការទូទាត់ ឬសំណងតាមទំរង់ផ្សេងៗនឹងត្រូវធ្វើជាចាំបាច់សំរាប់ហេតុប៉ះពាល់ដែលមិនអាចគណនាបាន។ ហេតុប៉ះពាល់អវិជ្ជមាន ក៏ត្រូវបង្ហាញជាតួលេខនៅក្នុងការវិភាគសេដ្ឋកិច្ច និងបរិស្ថាន ផងដែរ។ ដើម្បីធានាបានពីការរៀបចំឱ្យបានល្អ និងមានភាពរលូនសំរាប់ការសិក្សា វ.ហ.ប វិធីសាស្ត្រទូទៅមានរៀបរាប់ ដូចខាងក្រោម:

## ១. ការប្រមូលទិន្នន័យ និង ការពិនិត្យមើលរបាយការណ៍នានា

- ការប្រមូលទិន្នន័យជាក់ស្តែង និងទិន្នន័យដែលមានស្រាប់នៅ ទីក្រុងភ្នំពេញ និងខេត្តព្រះសីហនុ ទាក់ទងទៅនឹងច្បាប់ គោលនយោបាយ បទបញ្ញត្តិ ផែនការអភិវឌ្ឍ និងទិន្នន័យផ្សេងទៀតទាក់ទងទៅនឹងគំរោង ។
- ពិនិត្យមើលលើរបាយការណ៍នានា បាយការណ៍សមិទ្ធិលទ្ធភាពរបស់គំរោង និងប្លង់វិស្វកម្មលំអិត និងឯកសារទាក់ទងផ្សេងទៀតទៅនឹងការអនុញ្ញាតិឱ្យវិនិយោគរបស់គំរោង ។

## ២. ការជួបប្រជុំ និង ការពិគ្រោះយោបល់

- ការជួបប្រជុំ និងការពិគ្រោះយោបល់ជាមួយស្ថាប័នសំខាន់ៗដែលទាក់ទងទៅនឹងគំរោងត្រូវបានធ្វើឡើងនៅរាជធានីភ្នំពេញ (នាយកដ្ឋានមួយចំនួននៃក្រសួងបរិស្ថាន ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងធនធានទឹក) និងនៅក្រុងព្រះសីហនុ (សាលាខេត្តព្រះសីហនុ មន្ទីរបរិស្ថាន មន្ទីរសាធារណការនិងដឹកជញ្ជូន មន្ទីរទេសចរណ៍ មន្ទីរផែនការ មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល មន្ទីរសុខាភិបាល មន្ទីរអប់រំ ខ័ណ្ឌរដ្ឋបាលជលផល ខ័ណ្ឌរបាលព្រៃឈើ កំពង់ផែស្វ័យតកំពុងសោម និងអាជ្ញាធ័រមូលដ្ឋាន) និងស្ថាប័នពាក់ព័ន្ធដទៃទៀត។
- កិច្ចប្រជុំពិគ្រោះយោបល់ជាមួយនឹងសហគមន៍ ឬអ្នកភូមិនៅក្នុងតំបន់ទទួលរងផលប៉ះពាល់របស់គំរោង នៅភូមិមួយ ភូមិបី ក្នុងសង្កាត់បីនៃក្រុងព្រះសីហនុ ។
- សិក្ខាសាលានៅសាលាខេត្តព្រះសីហនុ ដែលចូលរួមដោយស្ថាប័នជាប់ទាក់ទងនឹងគំរោងថ្នាក់ជាតិ/កណ្តាល មន្ទីរជំនាញក្រោមឱវាទខេត្ត តំណាងអង្គការនានា និងភ្នាក់ងារឯកជន។

## ៣. ការចុះអង្កេតទៅលើធនធានធម្មជាតិ

- ភូគព្ភសាស្ត្រ និង ដី (ទិន្នន័យពីរបាយការណ៍សិក្សាសមិទ្ធិលទ្ធភាព/សិក្សាលំអិតរបស់គំរោង)

- ការថតរូបពីលើអាកាស Aerial photo លើតំបន់គំរោងទំហំ ៥.៧ គ.ម[២] ពណ៌ធម្មជាតិ គំរិត លំអៀង ០.៣ម ប្រើប្រព័ន្ធ UTM ខ្នាតជាម៉ែត្រ និងដែលទូម WGS84 ។
- ការសិក្សាលើធនធានព្រៃឈើ និងសត្វព្រៃនៅលើកោះពស់ទាំងមូល (ទំហំដី ១១៦ ហ.ត) (ក្នុងឯកសារភ្ជាប់ទី ១) ។
- ការសិក្សាត្រី ក្នុងតំបន់កោះពស់ រួមមាន : ប្រភេទត្រីនិងភាពសំបូរបែបរបស់ប្រភេទត្រី ប្រភេទត្រីកម្រ ជីវភាពប្រជាជនដែលពឹងផ្អែកលើការចាប់ត្រី ហេតុប៉ះពាល់លើត្រីក្នុងតំបន់គំរោង (ក្នុងឯកសារភ្ជាប់ទី ២) ។
- ការសិក្សាពិនិត្យអង្កេតផ្កាថ្មនៅជុំវិញកោះពស់ ក្នុងការកំណត់ ស្ថានភាពផ្កាថ្ម និងស្ថានភាពពពួកត្រីនិងពពួកនិបិដ្យជ្ជិតសត្វ (ក្នុងឯកសារភ្ជាប់ទី ៣) ។
- ការធ្វើតេស្ត ឬការពិនិត្យគុណភាពទឹក: ការធ្វើតេស្តនៅទីវាល ការយកគំរូសំណាកទឹក និងការធ្វើវិភាគក្នុងមន្ទីរពិសោធន៍នៅភ្នំពេញ (មន្ទីរពិសោធន៍គុណភាពទឹករបស់ក្រសួងបរិស្ថាន និងក្រសួងធនធានទឹក) ។
- ការពិនិត្យគុណភាពខ្យល់នៅក្នុងតំបន់គំរោង ដោយក្រុមអ្នកជំនាញមកពីមន្ទីរពិសោធន៍របស់ក្រសួងបរិស្ថាន ។

## ៤. ការចុះអង្កេតទៅលើធនធានសង្គម

- ដីប្រើប្រាស់: មានប្រើផែនទី JICA ឆ្នាំ ២០០៣ មាត្រដ្ឋាន ១:១០០០០០ Landsat (TM) ឆ្នាំ ២០០០ រូបថតពីលើអាកាសឆ្នាំ២០០១-២០០២ និងទិន្នន័យជាក់ស្តែងពីសង្កាត់បី ក្រុងព្រះសីហនុ ។
- ស្ថិតិប្រជាជនក្នុងតំបន់គំរោង និងកំណត់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់: ការចុះធ្វើអង្កេតក្នុងភូមិ ១ ភូមិ២ និងភូមិ៣ក្នុងសង្កាត់បី ក្រុងព្រះសីហនុ ។ ការសំយោគពីកំរងឯកសារឃុំសង្កាត់ ។
- ការអង្កេតលើការតាំងលំនៅដ្ឋានសារជាថ្មី បើសិនមានការផ្លាស់ប្តូរលំនៅដ្ឋាន ។
- ការអង្កេតលើសកម្មភាពអភិវឌ្ឍ/សេដ្ឋកិច្ចនៃសហគមន៍ក្នុងតំបន់គំរោង: ធ្វើបទសំភាសន៍តាមលំនៅដ្ឋាន និងសំយោគលើឯកសារមានស្រាប់ (ក្នុងឯកសារភ្ជាប់ទី ៤) ។
- ការសិក្សាអំពីសំណល់រឹង (សំរាម) នៅជុំវិញឆ្នេរកោះពស់ និងឆ្នេរបហាវៃ (ក្នុងឯកសារភ្ជាប់ទី ៥) ។
- ហេដ្ឋារចនាសម្ព័ន្ធបំរើឱ្យការប្រើប្រាស់របស់មនុស្ស និងគុណភាពនៃជីវិតរស់នៅ: ការចុះអង្កេតតាមភូមិឃុំផ្ទាល់ និងការសំយោគពីឯកសារមានស្រាប់ដែលពាក់ព័ន្ធ ។

Draft

## ៥. ការវិភាគ និង ការវាយតំលៃពីសក្តានុពលនៃហេតុប៉ះពាល់បរិស្ថាន

- ប្រើតារាងឆេកលីសសំរាប់ វ.ហ.ប
- ហេតុប៉ះពាល់ដែលកើតឡើងអំឡុងពេលរៀបចំប្លង់គំរោង/មុនពេលសាងសង់
- ហេតុប៉ះពាល់ដែលកើតឡើងអំឡុងពេលសាងសង់គំរោង
- ហេតុប៉ះពាល់ដែលកើតឡើងអំឡុងពេលប្រតិបត្តិគំរោង
- បណ្តុំនៃហេតុប៉ះពាល់
- ផលប៉ះពាល់ជាវិជ្ជមាន ដែលនឹងទទួលបានពីគំរោង

## ៦. ការវិភាគសេដ្ឋកិច្ច

- ប្រើលទ្ធផលវិភាគលើលទ្ធភាពហិរញ្ញវត្ថុ និងសេដ្ឋកិច្ចពីរបាយការណ៍សិក្សាសមិទ្ធិលទ្ធភាពគំរោង
- កំណត់តម្លៃបាត់បង់នៃធនធានធម្មជាតិ និងសង្គមដោយសារសកម្មភាពគំរោង
- ស្មានទុកជាមុននូវគុណប្រយោជន៍សេដ្ឋកិច្ច ដែលនឹងត្រូវទទួលបានពីគំរោង ។

## ៧. ការរៀបចំរបាយការណ៍ វ.ហ.ប

- របាយការណ៍ វ.ហ.ប មានទំរង់ទៅតាមគោលការណ៍ណែនាំរបស់ក្រសួងបរិស្ថាន សំរាប់ការសិក្សា វ.ហ.ប ចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០០៩ ។
- ផែនទី GIS និង រូបថតត្រូវបានដាក់បញ្ចូល ។
- ការដាក់បញ្ចូលវិធានការបន្ធូរបន្ថយដើម្បីកាត់បន្ថយទំហំនៃហេតុប៉ះពាល់ អំឡុងពេលរៀបចំប្លង់ ដំណាក់សាងសង់ និងដំណាក់កាលប្រតិបត្តិគំរោង ។
- ការប៉ាន់ប្រមាណតំលៃសំរាប់វិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន និងការត្រួតពិនិត្យបរិស្ថាន ការស្នើមូលនិធិបរិស្ថាន និងផលចំណេញរបស់គំរោង ។
- ការរៀបចំផែនការគ្រប់គ្រងបរិស្ថាន ដើម្បីប្រើប្រាស់កំឡុងពេលសាងសង់ និងប្រតិបត្តិការ ។

Draft

ដ្យាក្រាមសង្ខេបវិធីសាស្ត្រនៃការសិក្សារៀបចំរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ សំរាប់**គំរោងមរកត** ក្នុងខេត្តព្រះសីហនុ ប្រទេសកម្ពុជា




Draft